កំណាព្យ **សង្ឃឹមជានិច្ច** (បទ ពំនោល)

- សង្ឃឹមៗជានិច្ច ថ្ងៃរះហើយលិច លិចហើយគង់រះមិនខាន។
- នាវាកម្ពុជាថ្កើនថ្កាន បោះពួយឆ្ពោះស្ថាន សន្តិភាពសុខសាន្តប្រពៃ។
- សង្ឃឹមខ្មែរផ្លាស់ចិត្តថ្មី គំនិតវេញថ្មៃ សាមគ្គីរួមជាថ្លុងមួយ។
- ខ្មែរអើយអើយខ្មែរអស់ព្រួយ ខ្មែរលែងរំជួយ រំដើបឈ្លោះទាស់គ្នាឯង។
- សង្ឃឹមជានិច្ចជាក់ស្តែង ព្រោះខ្មែរសំដែង ឆន្ទៈស្រុះស្រួលមូលមិត្ត។
- សង្ឃឹមថាបានយល់ពិត សន្តិភាពពិសិដ្ឋ ពិសេសពិសាលថ្លាថ្លៃ។
- សង្ឃឹមប្រជាធិបតេយ្យ មានពិតលើដី ខ្មែរថ្មីល្បីរុងរឿងហើយ។
- សន្តិភាពមើលឃើញបង្កើយ ឪស ឪ!ខ្មែរអើយ កុំនៅតោះតើយដល់ណា។
- ប្រញាប់ប្រញាស់កុំរា ប្តូរមតិគ្នា ផ្តោះផ្តងស្ថាបនាជាតិយើង។
- សង្ឃឹមសភាដ៏ថ្កើង តំណាងជាតិយើង ថាពិតជាជួយដោះស្រាយ។
- បញ្ហាស្មុគស្មាញទាំងឡាយ កក្កូរកកាយ បកស្រាយយកមកវែកញែក។
- ទំលុះទំលាយឲ្យបែក សង្ឃឹមថ្ងៃស្អែក បែងចែកឲ្យដាច់ស្រឡះ។
- សង្ឃឹមជានិច្ចរឿងចាស់ ប្រែប្រួលក្រឡះ ប្តូរផ្លាស់ប្រែជាភ្លឺវិញ។
- គេងគិតរំពឹងទន្ទេញ ទុក្ខម្នោទោម្នេញ នឹងចេញបាត់ពីកាយា។
- សន្តិភាពមានដល់រដ្ឋា សុវណ្ណភូមិថ្លៃថ្លា រុងរឿងដូចមហាអង្គរ។
- សង្ឃឹមថាលែងរឹករ៉រ ប្រជាពលករ នឹងបានភិរម្យសុខា។
- សង្ឃឹមថាខ្មែរគ្រប់គ្នា ចូលរួមរស់ជា សាច់ឈាមតែមួយគឺខ្មែរ។
- សង្ឃឹមថាគ្មានកែប្រែ ទស្សនៈអ្នកស្នេហ៍ មិនងាកមិនវេត្រង់ល្អ។
- សង្ឃឹមជានិច្ចនូវពរ អស់ទេពនិករ ប្រោះព្រំបវរសួស្តី។
- សង្ឃឹមខ្មែរមានអរិយ ធម៌ដ៏ប្រពៃ រុងរឿងជានិរន្តរ៍អើយ។
- សង្ឃឹមៗដល់ត្រើយ ខ្មែររស់វិញហើយ រស់ហើយសង្ឃឹមជានិច្ច។

ចងក្រងដោយៈ អ្នកស្រី ជា ម៉ាក់សីន

សាលាបឋមសិក្សា ស្ទឹងមានជ័យ